# ១៩.រឿង ក្រពើឈ្មោះអាធន

(នៅស្រុកសម្បូរ ខេត្តក្រចេះ)

សម័យទីក្រុងតាំងនៅឧត្តុង្គ នៅស្រុកសម្បូរ ខេត្តក្រចេះ មានចៅអធិការវត្តមួយអង្គ ជាអ្នកប្រព្រឹត្តរៀន នូវវិជ្ជាវេទមន្តអាគម ហើយជាអ្នកចេះចិញ្ចឹមក្រពើផង ។ ឯចំណេះរបស់លោកគ្រូចៅអធិការ ដែលចេះចិញ្ចឹមក្រពើនោះ ធ្វើឲ្យលោកមានឈ្មោះល្បីល្បាញណាស់ ក៏ប៉ុន្តែចំណេះនោះបែរជាបណ្តាលឲ្យមានសេចក្តីអន្តរាយដល់រូបលោកទៅវិញ ។ លោកគ្រូចៅអធិការនោះ ចិញ្ចឹមក្រពើមួយទុកដូចជាកូនសិស្សរបស់លោក ក្រពើនោះនៅក្នុងទន្លេមេគង្គ ជាទន្លេដែលប្រកបដោយទឹកជ្រៅមានត្រីច្រើន ។ លោកឲ្យឈ្មោះក្រពើនោះថា "អាធន(២)" ។ ដោយលោកស្រឡាញ់ក្រពើនោះពេក លោកចូលចិត្តគង់លើថ្មនៅមាត់ច្រាំងទន្លេ ស្រែកហៅអាធនឲ្យមកលេងសប្បាយជាមួយលោក ។ អាធនបានឮពុទ្ធដីការបស់លោកគ្រូកាលណា ក៏វាប្រញាប់មកថ្វាយបង្គំលេងកម្សាន្ត សប្បាយជាមួយលោកគ្រូវាកាលនោះ ហើយតាំងកិរិយាសុភាពនឹងធឹង ចំពោះភិក្ខុសង្ឃទាំងអស់ និងអ្នកស្រុកទាំងអំបាលម៉ាន ដែលនៅជិតខាងវា ។

សម័យមួយ កាលព្រះមហាក្សត្រទ្រង់គង់ក្រុងឧត្តុង្គ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គ ទ្រង់ប្រឈួនជាខ្លាំង ។ ដោយព្រះអង្គស្រឡាញ់ព្រះរាជបុត្រីយ៉ាងខ្លាំងឥតឧបមា ព្រះអង្គទ្រង់ខ្សឹកខ្សួលតក់ស្លុតជាពន្លឹក ហើយទ្រង់ឲ្យជ្រើសរើសរកពេទ្យហ្ម ដែលពូកែមានឈ្មោះល្បីអស្ចារ្យ មកព្យាបាលព្រះរាជបុត្រីព្រះអង្គ ក៏ប៉ុន្តែគ្មានគ្រូឯណាមួយ អាចរំលែកទុក្ខព្រះរាជបុត្រីបានឡើយ ។ ហេតុនេះ បានជាព្រះមហាក្សត្រ ទ្រង់ឲ្យនិមន្តចៅអធិការវត្តសម្បូរ ដែលមានឈ្មោះល្បីពូកែជាងគ្រូពេទ្យឯទៀត មកព្យាបាល ។

ការធ្វើដំណើរតាមទន្លេមេគង្គដោយកប៉ាល់ ពីស្រុកសម្បូរទៅឧត្តុង្គ ក្នុងសម័យឥឡូវនេះ តែ ២ ថ្ងៃទេ តែក្នុងសម័យទីក្រុងតាំងនៅឧត្តុង្គនោះ គេធ្វើដំណើរដោយទូកជាយូរថ្ងៃ ព្រោះទន្លេនោះ មុនពេលទៅដល់ក្រចេះមានទឹកហូរស្រួលល្អទេ តែពីក្រចេះត្រូវឆ្លងទឹកហូរក្ដួចខ្លាំងៗ និងមានថ្មស្រួចៗ ដុះនៅក្នុងទឹកដោយអន្លើៗ ។

លោកគ្រូចៅអធិការនិមន្តមកព្យាបាលព្រះរាជបុត្រីៗ ក៏បានស្រាកស្បើយជំងឺ ធូរគ្រាន់បើ ប៉ុន្តែព្រះមហាក្សត្រទ្រង់ពុំអនុញ្ញាតឲ្យគ្រូចៅអធិការវិលទៅវិញភ្លាមទេ ទ្រង់ឲ្យលោកនៅរងចាំថែទាំជំងឺព្រះរាជបុត្រី ត្រាតែជាស្រឡះមែនទែនសិន ។

និយាយពី អាធន ដែលនៅស្រុកសម្បូរ វាទន្ទឹមមើលផ្លូវលោកគ្រូរបស់វា ជាយូរខែពុំឃើញវិលមកវិញសោះ វាកើតមានសេចក្តីស្រងូតស្រងាត់រលឹកដល់លោកគ្រូវាជាអនេក ។ ថ្ងៃមួយ វាព្រួយខ្លាំង វាក៏ហែលចេញពីទីលំនៅវា ទៅតាមដងទន្លេមេគង្គ ឆ្ពោះត្រង់ទៅតាមលោកគ្រូវានៅឧត្តុង្គ ។ វាធ្វើដំណើរពីស្រុកសម្បូរ ទៅដល់ឆ្លងគ្មានជួបប្រទះនឹងសត្រូវ ឬគ្មានអន្តរាយអ្វីដល់ខ្លួនវាសោះ ប៉ុន្តែលុះវាទៅដល់ដល់ភ្នំ ១ ឈ្មោះ "ភ្នំសុពណ៌កាលី" វាបានជួបនឹងក្រពើមួយ ជាក្រពើសាហាវក្លាហានឈ្លានពានណាស់ ដោយក្រពើនោះក្រេវ

ក្រោធនឹង អាធន ដែលហែលកាត់ទីលំនៅវាៗ ក៏រករឿងដាលវាលឈ្លោះ ប៉ុន្តែដោយ អាធន មានកិច្ចរួសរាន់ចង់ជួបនឹងលោកគ្រូវាៗ ក៏ដោះដៃរត់អំពីក្រពើកំណាចនេះទៅ តែវាតាំងចិត្តថា " ចាំថ្ងៃក្រោយ សឹមអញមករករឿងនឹងអាតិរច្ឆាននេះវិញ " ។ អាធន ទៅដល់កំពង់ហ្លួងគ្មាននរណាឃើញវាសោះ វាខំប្រុងប្រៀបលាក់ខ្លួនពួនអាត្មា មិនឲ្យអ្នកស្រុកឃើញវាឡើយ ពីព្រោះវាយល់ថា មុខតែគេភ័យផ្អើលរត់ចោលដីដៃទន្លេសាបអស់ ហើយវាព្រួយបារម្ភក្រែងរកលោកគ្រូវាពុំឃើញ ដោយលោកគ្រូវា ហើយនឹងវាខុសភេទគ្នាឆ្ងាយណាស់ ទាំងការចិញ្ចឹមជីវិតក៏ខុសគ្នាទៀត ប៉ុន្តែលុះវាជញ្ជឹងគិតទៅ វាតាំងចិត្តថា " ត្រូវតែអញលាក់ខ្លួនពួនអាត្មា នៅក្នុងទឹកនេះសិនចុះ ដើម្បីនឹងឆ្លៀតឈ្លបមើលលោកគ្រូ ក្រែងលោកចុះមកកម្សាន្តនៅក្បែរមាត់ច្រាំងតាមចំណាំរបស់លោក ដូចកាលមុនៗ មក " ។

មិនយូរប៉ុន្មាន លោកគ្រូចៅអធិការ ក៏និមន្តចុះទៅមាត់ច្រាំងទន្លេទៅគង់នៅលើផែមួយ ។ ឯ អាធន កាលបើលបមើលឃើញគ្រូវាហើយវាក៏បណ្តែតខ្លួនវាមកលើទឹកឲ្យគ្រូវាឃើញ ។ លោកគ្រូចៅអធិការក្រឡេកឃើញវាហើយ ក៏ភ្លាត់មាត់ស្រែកថា " យី អាធន ចៅតាទេតើនេះ " ។ អាធន មិនបង្អង់យូរ ក៏យកមាត់វាទៅបំបាក់ផែដែលលោកគ្រូគង់ ហើយត្រកងលោកគ្រូវាដាក់លើខ្នងវានាំយកទៅ ដោយវានឹកថា " ទោះបើលោកគ្រូអញ គ្មានព្រះទ័យប្រាថ្នានឹងវិលទៅទីលំនៅលោកវិញទេ ពេលនេះក៏ត្រូវតែអញនាំលោកទៅ " ។

ឱពុទ្ធោអើយ ! លោកគ្រូចៅអធិការនោះ លុះទៅដល់ស្រុកសម្បូរលោកក៏បាត់បង់ជីវិត ។ ពេលដែល អាធន នាំលោកគ្រូវាទៅពុំទាន់ដល់ភ្នំសុពណ៌កាលី វាខំប្រុងប្រយ័ត្នការពារលោកគ្រូវា មិនឲ្យជ្រមុជក្នុងទឹកសោះ វាហែលនៅសើៗលើទឹក លុះទៅភ្នំ សុពណ៌កាឡី វាជួបនឹងបច្ចាមិត្តវា ដែលរករឿងប្រយុទ្ធជាមួយវាពីថ្ងៃមុនដូចពណ៌នាមកហើយនោះ ។ ដោយសេចក្តីគុំកួនប្រណាំងប្រជែងនៅជិតជាប់នៅក្នុងចិត្ត សត្វពីរពុំចេះអស់ពុំចេះហើយ ក៏នាំឲ្យកើតក្តីជម្លោះឡើងជាថ្មីម្តងទៀត សត្វទាំងពីរក៏តាំងប្រយុទ្ធគ្នាក្នុងខណៈនោះភ្លាម ។ មុននឹងប្រយុទ្ធគ្នា អាធន គិតឃើញថា "ប្រសិនបើអញខាំក្រពើនេះ អញគេចចុះគេចឡើងគ្រវីគ្រវាត់ក្នុងទឹកសមជាលោកគ្រូអញធ្លាក់ពីលើខ្នងអញចុះទៅបាតទន្លេហើយ បើដូច្នេះអញគិតយ៉ាងណា នឹងរត់ភៀសខ្លួនកុំឈ្លោះនឹងអាកំណាចនេះឬដូចម្តេច ?" ជញ្ជឹងគិតទៅ ទើប អាធន មានគំនិតមួយថា "ទេគិតយ៉ាងនេះខុសទេ ធ្វើបែបនេះជាការនាំឲ្យបរាជ័យដល់វត្តសម្បូរពេក អញត្រូវតែប្រយុទ្ធច្បាំងនឹងអាចង្រៃនេះឲ្យវាដឹងខ្លួនថា តែកាលណាអាណាមួយហ៊ានតតាំងនឹងក្រពើលោកគ្រូចៅអធិការវត្តសម្បូរហើយ អានោះឯងមុខជាអន្តរធានខ្លួនពុំលែងឡើយ" ហើយវាគិតឃើញម្យ៉ាងទៀតថា" ដូច្នេះអញត្រូវតែយកលោកគ្រូអញលាក់ទុកក្នុងពោះអញសិន" ។ អាធន គិតដូច្នេះហើយ ក៏ហាមាត់លេបលោកគ្រូវាលាក់ទុកក្នុងពោះវាបាត់ទៅ ។ លុះលាក់លោកគ្រូរួចស្រេចហើយ ទើបវាយុទ្ធនឹងបច្ចាមិត្តរបស់វា មិនយូរប៉ុន្មាន អាធន មានជ័យជម្នះឈ្នះលើក្រពើជាសត្រូវ ហើយអាធន ក៏ធ្វើដំណើរទៅទៀតទាល់តែដល់ស្រុកសម្បូរ ។ បណ្តាភិក្ខុសង្ឃក្នុងវត្តនោះវេលាដែលឃើញ អាធន ទៅដល់ក៏នាំគ្នារត់ម្នីម្នាមកទទួល អាធនៗ ក៏វាឡើងទៅលើគោកនៅចំកណ្តាលភិក្ខុសង្ឃទាំងឡាយ ហើយក៏ខ្ជាក់លោកគ្រូវាចេញពីក្នុងពោះវាមក ។

ឱពុទ្ធោអើយ ! ពេលនោះលោកគ្រូបាត់វិញ្ញាណក្លាយទៅជាខ្មោចសុទ្ធសាធ ។ ឃើញអាការវិនាសដូច្នេះហើយ ភិក្ខុសង្ឃគ្រប់អង្គ ស្រែកទ្រហោយំទ្រហឹងអឺងកងស្តាយលោកគ្រូចៅអធិការ ហើយក៏បន្ទោសទៅអាធនថា "អាឯងនេះអាក្រក់ណាស់ ហ៊ានសម្រាប់លោកគ្រូឥតពិចារណា" ។ អាធន នឹកថា "ឱអញអើយ ! អញស្មានថាពោះអញ អាចលាក់លោកគ្រូអញ ឲ្យរួចពីក្តីអន្តរាយបាន ឥឡូវនេះ បែរត្រឡប់ទៅជាផ្ទុរ

សម្រាប់កប់លោកគ្រូអញទៅវិញសោះ ឱគំនិតអ្វីក៏ថយថោកម្ល៉េះ !“ អាធន នឹកទៅពេញហៅស្តាយលោកគ្រូវាណាស់ តែពុំដឹងធ្វើម្តេចឲ្យលោកមានជីវិតឡើងវិញ ។ វេលាគេរៀបបូជាសពលោកគ្រូថៅអធិការ អាធន មានសេចក្តីអៀនខ្មាសខ្លាំង ហើយនឹកថា "អពមង្គលដែលនាំឲ្យលោកគ្រូអញដល់សេចក្តីវិនាសយ៉ាងនេះតើមកពីហេតុអ្វី ?" ។ ជញ្ជឹងគិតយូរទៅ វាសន្និដ្ឋានថា "អញប្រាកដជាខុសពិតមែនហើយ ព្រោះអញបានសម្លាប់លោកគ្រូដោយខ្លួនអញ ប៉ុន្តែហេតុអ្វី បានជាអញលេបលោកគ្រូទៅក្នុងពោះអញ ? នេះមកអំពីអញការពារសត្រូវនៅ ភ្នំសុពណ៌កាឡី ក្នុងពេលដែលត្រឡប់ពីឧត្តុង្គវិញ" ។ ប៉ុន្តែយូរបន្តិចទៅទៀត អាធន គិតឃើញច្បាស់ថា "សេចក្តីអន្តរាយដែលកើតឡើងអម្បាលនេះ បណ្តាលមកតែអំពីព្រះរាជបុត្រី បើប្រសិនជាស្តេចកុំត្រាស់បង្គាប់ឲ្យគេនិមន្ត លោកគ្រូអញឲ្យទៅមើលជំងឺព្រះរាជបុត្រីព្រះអង្គ ច្បាស់ជាលោកគ្រូអញលោកពុំមានគ្រោះថ្នាក់ដល់មរណៈដូច្នេះឡើយ ហេតុដែលបណ្តាលឲ្យគ្រូអញដល់មរណៈ ដោយសារតែព្រះរាជបុត្រី ដូច្នេះ ព្រះរាជបុត្រីត្រូវតែមានទោស " ។ គិតហើយ អាធន ក៏ចងអាឃាតគំនុំគុំកួនប្រុងសងសឹកនឹងព្រះរាជបុត្រី ឲ្យដល់នូវសេចក្តីមរណៈ ហើយអាធន ក៏វាពីលើគោកចុះទៅក្នុងទឹកទន្លេមេគង្គ ។ ឱ! គួរឲ្យស្តាយវត្តសម្បូរណាស់ អស់បានឃើញអាធន ទៀតហើយ ។ មុននឹងហែលទៅដល់ឧត្តុង្គ អាធន ហែលសន្សឹមៗ ជាយូរថ្ងៃ នៅក្នុងទន្លេមេគង្គ ។ ដល់ឧត្តុង្គ ទើបវាឈប់សម្រាកកាយ បង្អង់ចាំមើលឱកាសល្អដើម្បីសងសឹកនឹងព្រះរាជបុត្រី ។

ក្នុងរឿងនេះ គេមិនបានរ៉ាយរ៉ាប់អំពីកំណត់ប៉ុន្មានឆ្នាំឬខែ ដែលក្រពើបង្អង់ចាំមានឱកាសល្អនឹងសងសឹកឡើយ គេគ្រាន់តែនិយាយថា " មានថ្ងៃមួយ វេលាដែលព្រះរាជបុត្រីនោះ បានជាសះស្បើយស្លើយស្រួលព្រះអង្គហើយ ព្រះនាងចុះមកក្រសាលទឹកទន្លេជាមួយនឹងបរិពាររបស់ព្រះនាង ។ វេលាដែលព្រះនាងកំពុងកញ្ជ្រោងបោកបាចលេងសប្បាយ សើចក្អាកក្អាយជាមួយនឹងព្រះរាជបរិពារនៅក្នុងទឹកស្រាប់តែក្រពើឈ្មោះអាធន មកត្របាក់យកព្រះនាងទៅបាត់ទៅ ។

និយាយពីព្រះមហាក្សត្រ កាលបើទ្រង់ជ្រាបហេតុថា ក្រពើបានត្របាក់លេបព្រះរាជបុត្រីហើយ ក៏ទ្រង់ព្រះកន្សែងខ្សឹកខ្សួលអួលអាក់ជាខ្លាំងពន់ពេក ទ្រង់ត្រាស់បង្គាប់ឲ្យរៀបចំទូកទៅតាមប្រហារជីវិតក្រពើនោះ ។

ដើម្បីឲ្យច្បាស់នូវរឿងនេះ យើងគប្បីសន្និដ្ឋានថា "នៅក្នុងសម័យនោះ ប្រទេសកម្ពុជាលិចទឹកពាក់កណ្តាលកន្លែងមួយធំដែលឥឡូវនេះ ជាខេត្តកំពង់ចាមនិងក្រចេះ លិចទឹករហាចរហឹមទាំងអស់" ។ ហេតុដូច្នេះបានជាមានសត្វទឹកច្រើនមហិមា ។ ដើម្បីនឹងទៅប្រហារជីវិត អាធន នោះ គេត្រូវរៀបសំពៅរៀបទូកក្តារច្រវាថែវច្រើន ។ នៅទីបំផុត ព្រះរាជាទ្រង់ព្រះបញ្ញាឲ្យហោរាគន់គូរមើលឲ្យដឹងថាក្រពើនោះនៅទីណា ហើយឲ្យរកឧបាយកលតាមចាប់ក្រពើនោះឲ្យទាល់តែបាន ។ ហោរាបានឲ្យធ្វើកន្ទោងស្លឹកចេក ១ បញ្ចុះយន្តមន្តអាគមគាថា ក្នុងកន្ទោងនោះ ហើយបណ្តែតទៅលើទឹក ។ កន្ទោងនោះក៏អណ្តែតទៅតាមដាន អាធន ។ មុនដំបូងកន្ទោងអណ្តែតចេញ ពីឧត្តុង្គតម្រង់ទៅស្រុកសម្បូរ ហើយទៅសំចតក្នុងព្រែកមួយ ។ ខណៈដែលកន្ទោងសំចតត្រង់ណា គេដឹងថា កន្លែងនោះហើយដែលអាធន វាលាក់ខ្លួនពួនអាត្មាវា ។

លុះព្រះមហាក្សត្រ ទ្រង់បានជ្រាបទីលំនៅ របស់ អាធន ហើយទ្រង់ក៏ចាត់ឲ្យរៀបព្រួលនៅក្នុងទឹក ដើម្បីនឹងឃាំងព័ទ្ធ អាធន កុំឲ្យវាហែលរួចទៅក្នុងទន្លេ ។ ប៉ុន្តែចាត់ការពុំរហ័សទាន់ពេលវេលា អាធន ក៏ហែលរត់បាត់ពីកន្លែងនោះទៅ ។ ព្រែកដែលបានពោលមកនេះ មានឈ្មោះថា "ព្រែកចារធ្នល់ " ដែលមាននៅលុះដល់

សព្វថ្ងៃនេះ ។ ក្រោយពេលដែលវាបានហែលបត់ចុះបត់ឡើងគ្រប់ៗកន្លែង វាទៅដល់ស្រុកខោន ហើយវាសំចតនៅទីនោះ ២–៣ ថ្ងៃទើបវាហែលចុះមកវិញ ។ ឯកន្ទោងក៏ចេះតែអណ្ដែតតាមវាជាដរាប មានទាំងនាវា ២–៣ តាមកន្ទោងនោះផង ។ នៅទីបំផុត កន្ទោងនោះ ចុះមកដល់ស្រុកឆ្លូង អណ្ដែតចូលទៅក្នុងព្រែកឆ្លូង ។

ព្រែកឆ្លូងសម័យនោះ ក្នុងពោះព្រែកមានច្រើនតែភក់ល្បាប់ មាត់ព្រែកមានច្រើនតែគុម្ពោតព្រៃឈើ អ្នកស្រុកសង់ផ្ទះតូចៗ តាមជួរមាត់ព្រែកនោះ ក្នុងចន្លោះជលជាត និងគុម្ពោតព្រៃឈើទាំងនោះ ។ កាលដែល អាធន វាបានទៅដល់គុម្ពោតព្រៃទាំងនោះ វាសង្ឃឹមថាវាមុខជានឹងរួចអំពីគ្រោះថ្នាក់ធំហើយៗ វាសំចតនៅទីនោះ ។ គុម្ពោតព្រៃទាំងនោះ អាចបង្ខាំងមិនឲ្យទូកក្ដារនានាចូលបាន ប៉ុន្តែកន្លែងនោះហើយដែល អាធន បានសេចក្ដីអន្តរាយជាទម្ងន់រហូតដល់ស្លាប់ ។

និយាយអំពីបណ្ដាជនដែលដេញតាម អាធន កាលបើដឹងថា វាសំណាក់អាស្រ័យនៅទីនោះហើយ គេក៏នាំគ្នាទៅបញ្ជាន់មេមត់ ដែលជារូបសំណឹងអ្នកតាចាស់ស្រុកនៅទីនោះ ដណ្ដឹងសួរបន់ស្រន់ឲ្យជួយចាប់ អាធន់ យកមកប្រហារជីវិតឲ្យបាន បើបានដូចសេចក្ដីប្រាថ្នា គេនឹងថ្វាយស្បែកក្រពើដល់មេមត់នោះ ។ ពេលនោះ អាធន សំចតនៅកន្លែងមួយ ដែលហៅថាតាមសព្វថ្ងៃនេះថា " រូង " ។ ឯពួកអ្នកដេញតាម អាធន លុះបានឱកាសល្អក៏មុជក្នុងទឹកចាប់ចងស្រោក់ខ្លួនវា ។ ទីដែលធ្វើការទាំងនោះ នៅមានឃើញស្នាមដំណែលរហូតដល់សព្វថ្ងៃ ។ ដោយ អាធន មានទម្ងន់ច្រើនហាបពេក ទើបគេយកខ្សែចងដងថ្លឹងយឹតយោងថ្កក់យកខ្លួនវាឡើងមកសម្លាប់ ។

លុះសម្លាប់ អាធន បានស្រេចហើយ គេយកស្បែកទៅថ្វាយមេមត់ដែលបានបន់ពីមុនមក ។ កន្លែងដែលគេទុកដុំសាច់ក្រពើនោះ ជាប់ឈ្មោះថា "នាងក្រពើ" តមក ប៉ុន្តែដោយដីនៅកន្លែងនោះមានរាងដូចជាខ្នងសត្វលា (?) គេត្រឡប់ជាហៅថា " ខ្នងក្រពើ "វិញ ដែលជាកន្លែងធ្វើចម្ការកៅស៊ូនៅមេមត់សព្វថ្ងៃ ។ ឆៀងខាងកើតបន្តិចមកខាងស្នួលមានកន្លែងមួយឈ្មោះថា " វាលហាលងៀត " ព្រះជាកន្លែង ដែលគេពន្លះសាច់ អាធន ប្រឡាក់អំបិលហាលថ្ងៃ ។

ចំណែកព្រះសពព្រះរាជបុត្រី ដែលរកឃើញនៅក្នុងពោះ អាធន នោះ ព្រះរាជាទ្រង់ចាត់ការបូជាព្រះភ្លើងនៅស្រុកសម្បូរ ហើយទ្រង់បញ្ចុះព្រះធាតុក្នុងព្រះចេតិយមួយ នៅក្នុងវត្តសម្បូរនោះឯង ។